ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៦

***ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាទីគោរពជ**ន់ខ្ពស់ !*

ក្នុងឱកាសដ៏មហាវិសេសវិសាល ពោរពេញដោយសេចក្តីសោមនស្សរីកាយ ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦ ខាងមុខនេះ: តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងកវីយា សូមជូននូវសព្វសាធុការពរជ័យ សិរីមង្គល វៃុលសុខ មហាប្រសើរ ជូនចំពោះ: **ឯកឧត្តមកិត្តិ**:**សេដ្ឋាបណ្ឌិត** សូមទទួលបាននូវសុខភាពល្អហើបូរ កម្លាំងកាយមាំមួន បញ្ញាញាណវៃ ជន្មាយុយឺនយូរ ដើម្បីអមចំណែកជាមួយការជ័ដ្ឋាកិបាលក្នុងការពង្រឹងខឿនសេដ្ឋកិច្ចជាតិឱ្យកាន់តែរឹងមាំ និងអភិវឌ្ឍប្រទេសជាតិឱ្យកែចម្រើនរុងរឿងលើគ្រប់វិស័យ។

ម្យ៉ាងទៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងកោតសរសើរដោយស្មោះស្ម័គ្រចំពោះ: **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ដែលតែងតែខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ত ប្រាជ្ញាស្មារតី ប្រកបដោយធន្ធ:មនសិការដ៏មោះមុតក្នុងការអភិវឌ្ឍវិស័យផ្នែកការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមកិច្ច បាននាំមកនូវប្រយោជន៍ដ៏ឧត្តុង្គឧត្តមជូនសង្គមជាតិ សំដៅសម្រេចបាននូវនិរន្តរភាព ឯកភាពជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ស្ថិរភាព និងសន្តិសុខសណ្តាប់ធ្នាប់ ប្រកបដោយស្វាមីភក្តិចំពោះប្រទេសជាតិ ។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងកវីយា សូមបួងសួងចំពោះគុណបុណ្យព្រះតនត្រ័យ និងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាវ៉ែលក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះប្រាំនូវសព្វសាធុការពរជ័យជូន **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ: វណ្ណ: សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ១ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១ ឆ្នាំ២០២៥
នាយឧត្តមសេនីយ៍ ជៀ សីហា

ទីស្នាក់ការក្រសួង សង្កាត់ទន្លេបាសាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៥២៥ email: generalsec@mod.gov.kh

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

អរគុណសន្តិភាព! អរគុណនយោបាយឈ្នះឈ្នះ!